អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែង ទស្សទាយសម្ភារធ្វើពីអ្វី?**

**វិទ្យាសាស្ត្រ (ការរស់នៅប្រចាំថ្ងៃ)** ៖ ការស្វែងយល់ដោយសង្កេត

**ភាសាខ្មែរ (ការប្រើពាក្យតាមវេយ្យាករណ៍)**៖ ការយល់ពីវេក្យស័ព្ទ ឃ្លា និងល្បះ

**គោលបំណង** ៖

**វិទ្យាសាស្ត្រ** ៖ ពិសោធន៍ និងស្វែងយល់ដោយប្រើប្រាស់សម្ភារផ្សេងៗ ក្នុងការលេងដូចជា អណ្ដែត ជ្រាបទឹក និងមិនជ្រាបទឹក វត្ថុរលាយ និងមិនរលាយ ការលាយពណ៌ បណ្ដុះគ្រាប់ធញ្ញជាតិ ខ្យល់ជាដើម។

**ភាសាខ្មែរ** ៖ ប្រាប់បានពីពាក្យដែលទាក់ទងនឹងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ និងសកម្មភាពចាំបាច់មួយចំនួន និងនិយាយជាឃ្លា ល្បះ ឱ្យបានច្បាស់ពីប្រធានបទអ្វីមួយដោយមិនចាកប្រធាន។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សម្ភារមួយចំនួនដែលធ្វើពីថ្ម ឈើ ជ័រប្លាសស្ទីកជាដើម…

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**ការរៀបចំ** ៖ ដាក់សម្ភារទាំងនោះនៅក្នុងប្រអប់មួយ រៀបសម្ភារទាំងនោះឱ្យបានរួចរាល់

**សេចក្ដីណែនាំ**៖

(ល្បែងនេះលេងក្រោយពីក្មេងៗស្ដាប់រឿងនិទានរួច «យើងអាច គ្រាន់តែតាមវិធីផ្សេងគ្នា»ក៏បាន។)

1. និយាយប្រាប់ក្មេងៗពីជនពិការភ្នែក ដែលអានសៀវភៅដោយប្រើសៀវភៅអក្សរស្ទាប។
2. បង្ហាញពីឧទាហរណ៍ដោយបិទភ្នែកជាមួយកន្សែង ឬក្រណាត់ ។
3. បង្ហាញក្មេងៗថាថ្ងៃនេះពួកយើងនឹងសម្ដែងធ្វើជាពិការភ្នែកដូចជា ចិន្ដាដែរ ។
4. ពួកគេត្រូវបិទភ្នែកដោយកន្សែង ឬក្រណាត់ បន្ទាប់មកលូកចាប់យកសម្ភារមួយ និងទាយថាសម្ភារនោះឈ្មោះអ្វី? និងធ្វើអំពីអ្វី?
5. ក្មេងៗដែលនៅកន្លែងត្រូវនៅឱ្យស្ងៀម កុំប្រាប់ឱ្យសោះ។

6. ប្រសិនបើពួកគេទាយមិនត្រូវយូរពេក អាចប្រាប់តម្រុយពួកគេតិចៗបាន ដើម្បីឱ្យពួកគាត់ងាយក្នុងការទាយថាជាសម្ភារអ្វី និងធ្វើពីអ្វី?
7. ជ្រើសរើសក្មេងផ្សេងទៀតសម្រាប់លេងបន្ត រហូតដល់ចប់ល្បែងជាការស្រេច។

**ការប្រែប្រួល៖**

ល្បែងនេះអាចលេងដោយប្រើសម្ភារផ្សេងៗបាន ដូចជា ផ្លែឈើ បន្លែ ឬសម្ភារផ្សេងៗទៀត។ ល្បែងនេះអ្នកអាចលេងត្រឹមតែសួរក្មេងៗថាសម្ភារទាំងនោះឈ្មោះអ្វី? ក៏បានដែរដោយគ្រាន់តែធ្វើការស្ទាបតែប៉ុណ្ណោះ។